# កម្ពុជាក្រោម

## ស្វែងរកសិទ្ធិសេរីភាពជូនខ្មែរក្រោម

និពន្ធដោយលោក ថៅ ស៊ីវុត្ថា សមាជិកសកម្មរបស់

សហព័ន្ធខ្មែរកម្ពុជាក្រោម រដ្ឋអូរេហ្គិន សហរដ្ឋអាមេរិក ។

ខ្មែរកម្ពុជាក្រោមព្រមព្រៀងគ្នា សាមគ្គីសាមគ្គាប្រឹងរំដោះ
ទឹកដីមាតុភូមិធ្លាប់មានឈ្មោះ ពួកយួនប្រឹងឈ្លោះដណ្តើមយក ។
ខ្មែរកម្ពុជាក្រោមមិនព្រមស្ងៀម ចាំត្រៀមប្រឆាំងរៀងរាល់ថ្ងៃ
ក្បួនអហឹង្សាមាគារថ្មី ទាមទាទឹកដីតាមសន្តិវិធី ។
ខ្មែរកម្ពុជាក្រោមមានសង្ឃឹម ទន្ទឹមដោយមានអន្តរជាតិ
គាំទ្ររំដោះយ៉ាងព្រោងព្រាត ច្រើនសាសន៍ច្រើនជាតិគេប្រឹងជួយ ។
ខ្មែរកម្ពុជាក្រោមមានសហព័ន្ធ សាសន៍យួនបំពាន់មិនបានឡើយ
គៀបខ្លាំងពីខ្លាំងប្រឹងមិនកន្តើយ លុះត្រាដល់ត្រើយអនាគតដ៏ខ្ពី ។
ខ្មែរក្រោមព្រមអង្គាសហប្រជាជាតិ ធ្វើការពុំរាតផ្អៀតមិនទំនេរ

យកជ័យជំនះប្រគល់អោយខ្មែរ    កម្ពជាក្រោមបានល្ហែឃើញពន្លឺ ។

ខ្មែរកម្ពុជាក្រោមទ្រាំប្រឹងរស់    រក្សាកេរ្តិ៍ឈ្មោះខ្មែរតស៊ូ

រំដោះទឹកដីមិនព្រមប្រឹងថ្នូរ    ប្រឹងទុកគំរូមិនព្រមចុះចាញ់ ។

សូមខ្មែរកម្ពុជាក្រោមរួបរួមគ្នា    បើគ្មានសាមគ្គីសាមគ្គាខ្មែរត្រូវចាញ់

សត្រូវគ្រប់ទិសវាប្រវាញ់    បើឃើញខ្មែរចាញ់វាសប្បាយ ។

ខ្មែរកម្ពុជាក្រោមឈាមក្រហម    ផ្អិនផ្អៅមិនព្រមចាញ់ថយក្រោយ

ទៅមុខជានិច្ចមិនបណ្តោយ    ខ្មែរមិនព្រមខ្សោយអោយសត្រូវឈ្លានពាន ។

ខ្មែរកម្ពុជាក្រោមត្រូវតែឈ្នះ    សត្រូវវិនាសបើខ្មែរក្រោមប្រឹង

កុំឈរនៅស្ងៀមចាំសម្លឹង    ប្រឹងយកជោគជ័យជូនមាតុភូមិ ។

ខ្មែរកម្ពុជាក្រោមតស៊ូជានិច្ច    យួនប្រឹងពន្លិចខ្មែរប្រឹងស្ទុះងើប

យួនប្រើល្បិចចាក់ខ្មែរឈប់រសើប    ក្បាលឈឺប្រឹងងើបទើបយើងដល់ត្រើយ ។

ខ្មែរកម្ពុជាក្រោមដូចជានាវា    ប្រឹងចែវគ្រប់គ្នាយ៉ាងក្លាហាន

សត្រូវព្រហើនខ្មែរត្រូវតែហ៊ាន    ខំរុញខំច្រានទើបបានសម្រេច ។

ខ្មែរកម្ពុជាក្រោមគ្រប់ស្រទាប់    អ្នកត្រូវទម្លាប់ស្នេហាជាតិ

បើអ្នកនៅស្ងៀមខ្មែរត្រូវខាត    សត្រូវចូលឆ្មៀតញញឹមយក ។

ខ្មែរកម្ពុជាក្រោមមានឈាមខ្លាំង    តតាំងទប់ទល់យ៉ាងអំណាត់

ទោះបីឃ្លាតឆ្ងាយហើយនៅតែគិត    បងប្អូនញាត្តិមិត្តសង្ឃឹមទុក ។

ខ្មែរកម្ពុជាក្រោមត្រូវតែរស់ គំនិតមុតមោះមិនចុះចាញ់
ចូកចែវនាវាយ៉ាងត្របាញ់ ខ្នាន់ខ្នាញ់ត្របុលរុលទៅមុខ ។
ខ្មែរកម្ពុជាក្រោមជើងមិនរាទឹក ល្ហឹកណាដង្ហើមរស់ចិត្តស្មោះស
នាវាត្រូវលឿនត្បិតអ្នកចែវល្អ គំនិតបវរជួយចូកចែវគ្នា ។
ខ្មែរកម្ពុជាក្រោមច្រើនឆ្លាតវៃ រំពឹងរំពៃប្រមូលគ្នីគ្នា
ពុះពារឧបសគ្គខំធ្វើការ សម្រេចក្តីប្រាថ្នាលុះត្រាអវសាន ។

សូមអរព្រះគុណ សូមអរគុណ ។
ដោយស្មោះ

ថៅ ស៊ីវុត្ថា

អាលូហា ថ្ងៃទី ២០ មករា ២០១១